Khmer | ភាសាខ្មែរ



# តើត្រៀមខ្លួនដើម្បីចាប់ផ្តើមចូលរៀនថ្នាក់បឋមសិក្សាហើយឬនៅ?

ឥឡូវនេះកូនរបស់អ្នកចូលអាយុ 5 ឆ្នាំហើយ។ ដល់ពេលដែលត្រូវគិតអំពីការចុះឈ្មោះពួកគេឲ្យចូលរៀនថ្នាក់បឋមសិក្សាហើយ។

ឆ្នាំដំបូងនៃសាលាបឋមសិក្សាត្រូវបានគេហៅថា ថ្នាក់មូលដ្ឋាន (ថ្នាក់ត្រៀម)។ កុមារអាចចាប់ផ្តើមថ្នាក់មូលដ្ឋានបាន ប្រសិនបើពួកគេចូលអាយុ 5 ឆ្នាំ ត្រឹមថ្ងៃទី 30 ខែមេសា ក្នុងឆ្នាំដែលពួកគេចាប់ផ្តើមចូលរៀន។

ការសិក្សាគឺជាកាតព្វកិច្ចខានមិនបានសម្រាប់កុមារដែលមានអាយុ 6 ឆ្នាំ។

## របៀបចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សារដ្ឋក្នុងរដ្ឋវិចថូរៀ

### មុនពេលអ្នកដាក់ពាក្យ

- ពិចារណាថាតើកូនរបស់អ្នកអាចចាប់ផ្តើមចូលរៀននៅឆ្នាំណា ដោយផ្អែកលើអាយុរបស់ពួកគេ
- ស្វែងរកសាលារៀន និងតំបន់សាលារៀនរបស់អ្នកនៅតាមគេហទំព័រ **findmyschool.vic.gov.au**
- ទាក់ទងសាលាបឋមសិក្សាចាប់ពីត្រីមាសទី 1 ដើម្បីកក់ដំណើរទស្សនកិច្ចសាលារៀន (តាមការស្ម័គ្រចិត្ត)។

### របៀបដាក់ពាក្យសុំ

- ការដាក់ពាក្យសុំចូលរៀនថ្នាក់មូលដ្ឋាន (ថ្នាក់ត្រៀម) បើកពីដើមត្រីមាសទី 2
- ដាក់ពាក្យសុំរបស់អ្នកត្រឹមថ្ងៃសុក្រចុងក្រោយនៃខែកក្កដា
- សាលារៀននឹងទាក់ទងមកអ្នកជាមួយនឹងលទ្ធផលក្នុងរយៈពេល 2 សប្តាហ៍ដំបូងនៃខែសីហា។

ស្វែងយល់បន្ថែមនៅតាមគេហទំព័រ
**vic.gov.au/enrolling-foundation-prep**

The Education State

VICTORIA State Government | Department of Education